ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 18 / 09 / 2015
ម៉ោង (Time/Heure): 11:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

002/19-09-2007-ECCC/TC
E1/337

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

## កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

## សាធារណៈ

## សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសង

## ថ្ងៃ ចន្ទ ទី ២៦ ខែ សីហា ឆ្នាំ ២០១៥

## សវនាការលើភស្តុតាង - ថ្ងៃ ៣១៨

រៀបចំដោយ៖ សែ កុលវុឌ្ឍី និង **Matthew McCARTHY**

| |
|---|
| **កំណត់ហេតុអ្នកចូលរួម** |
| ចំពោះមុខ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម យ៉ា សុខន, ចៅក្រម Claudia FENZ , ចៅក្រម Jean-Marc LAVERGNE , ចៅក្រម យូ ឧត្តរា |
| ចៅក្រមបម្រុង៖ ចៅក្រម Martin KAROPKIN, ចៅក្រម ធូ មណី |
| ក្រឡាបញ្ជី៖ លោកស្រី សែ កុលវុឌ្ឍី, Matthew McCARTHY |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក William Smith, លោក Vincent de Wilde d'Estmael, លោក Travis FARR, កញ្ញា សុង ឆវ័ន្ត |
| ជនជាប់ចោទ៖ លោក នួន ជា (ពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ), លោក ខៀវ សំផន |
| ក្រុមមេធាវីការពារឲ្យជនជាប់ចោទ នួន ជា៖ លោក Victor KOPPE, លោក លឺវ សុវណ្ណា, លោក សុន អារុណ |
| ក្រុមមេធាវីការពារឲ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន, លោក Arthur VERCKEN, |
| ក្រុមមេធាវីប្រចាំការសម្រាប់ជនជាប់ចោទ ខៀវ សំផន៖ លោកស្រី ទូច វរល័ក្ស, លោក Calvin SAUNDERS |
| មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ លោកស្រី Marie GUIRAUD, លោក វ៉ែន ពៅ, |

| |
|---|
| លោក ពេជ អង្គ, លោកស្រី Lyma NGUYEN, លោកស្រី ជេត វណ្ណលី |
| សាក្សី/ដើមបណ្តឹង៖ |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អរុណ |
| ផ្សេងៗ៖ លោក ឡុង ង៉ែត, លោក ឈន សុខកុមារ, លោក នូ មនោរ័ត្ន, លោក Richard LATTA |

| **ពេលវេលាទូទៅរបស់តុលាការ៖** | | |
|---|---|---|
| ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០១៥ | ចាប់ផ្តើមម៉ោង៖ ០៩.១៤ | បញ្ចប់ម៉ោង៖ ១១.១៦ |
| សម្រាកពេលព្រឹក | ចាប់ផ្តើមម៉ោង៖ ១០.០៩ | បញ្ចប់ម៉ោង៖ ១០.៣៥ |
| សម្រាកថ្ងៃត្រង់ | ចាប់ផ្តើមម៉ោង៖ គ្មាន | បញ្ចប់ម៉ោង៖ គ្មាន |
| សម្រាកពេលរសៀល | ចាប់ផ្តើមម៉ោង៖ គ្មាន | បញ្ចប់ម៉ោង៖ គ្មាន |
| | ចំនួនម៉ោងសរុបរបស់តុលាការ៖ | ០១ ម៉ោង និង ៣៦ នាទី |

| **កិច្ចដំណើរការនីតិវិធីផ្សេងទៀត** | | | |
|---|---|---|---|
| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្តើម | ម៉ោងបញ្ចប់ |
| ការប្រកាសបើកកិច្ចដំណើរការសវនាការ និងការប្រកាសពីវត្តមានរបស់ភាគី | អង្គជំនុំជម្រះ<br>ក្រឡាបញ្ជី | ០៩.១៥<br>០៩.១៦ | ០៩.១៥<br>០៩.១៦ |
| សំណើរបស់ នួន ជា ស្នើសុំតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ | មេធាវីការពារក្តី នួន ជា | ០៩.១៦ | ០៩.១៦ |
| ការជំទាស់របស់មេធាវីការពារក្តី ខៀវ សំផន | មេធាវីការពារក្តី ខៀវ សំផន<br>សហព្រះរាជអាជ្ញា | ០៩.២៤<br>០៩.៣៨ | ០៩.៣៨<br>១០.០៩ |
| ការបង្ហាញឯកសារគន្លឹះរបស់សហព្រះរាជអាជ្ញា | សហព្រះរាជអាជ្ញា | ០៩.៣៨ | ១១.១៦ |
| ការជំទាស់របស់មេធាវីការពារក្តី នួន ជា | មេធាវីការពារក្តី នួន ជា | ១០.៣៥ | ១១.០០ |

**សេចក្តីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖**

**ការប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការ និងការប្រកាសពីវត្តមានរបស់ភាគី**

ប្រធានអង្គជំនុំជម្រះប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការ។ ក្រឡាបញ្ជីរាយការណ៍ថា គ្រប់ភាគីទាំងអស់មានវត្តមាន។ ដោយឡែកជនជាប់ចោទ នួន ជា មានវត្តមាននៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។

**សំណើរបស់ នួន ជា សុំតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ**

អង្គជំនុំជម្រះសម្រេចអនុញ្ញាតតាមសំណើរបស់ជនជាប់ចោទ នួន ជា ដែលបានស្នើសុំលះបង់សិទ្ធិចូលរួមកិច្ចដំណើរការនីតិវិធីដោយផ្ទាល់ក្នុងសាលសវនាការ និងអនុញ្ញាតឱ្យគាត់តាមដានកិច្ចដំណើរការនីតិវិធីសវនាការពីបន្ទប់ឃុំខ្លួនស្ថិតនៅខាងក្រោមសាលសវនាការ។

**ការជំទាស់របស់មេធាវីការពារក្តី ខៀវ សំផន ទៅនឹងការបង្ហាញឯកសារគន្លឹះរបស់ព្រះរាជអាជ្ញា**

សហព្រះរាជអាជ្ញាអន្តរជាតិ បានបង្ហាញឯកសារគន្លឹះទាក់ទងនឹងការដ្ឋានទំនប់០១មករា។ មេធាវីការពារក្តី ខៀវ សំផន បានជំទាស់ថាការបង្ហាញឯកសារគន្លឹះរបស់សហព្រះរាជអាជ្ញានេះ មិនគួរអនុញ្ញាតឱ្យមានការពិភាក្សាទៅលើការទទួលយកឯកសារនោះទេ និងបានជំទាស់ទីមួយ ទៅនឹងការប្រើប្រាស់ឯកសាររបស់ព្រះរាជអាជ្ញាពីឯកសារ D195.7 (មានការច្រលំជាមួយឯកសារ "E195.7")។ មេធាវីការពារក្តី ខៀវ សំផន បានកត់សម្គាល់ឃើញថា ឯកសារនេះមិនទាន់មានការទទួលយកជាភស្តុតាងនោះទេ។ ទីពីរ មេធាវីការពារក្តី ខៀវ សំផនក៏បានជំទាស់ទៅនឹងការដាក់បង្ហាញឯកសារ E342.1 ដែលនៅក្នុងឯកសារនេះទើបតែមានការទទួលយកជាភស្តុតាងតែ២ទំព័រប៉ុណ្ណោះ។ ចុងក្រោយមេធាវីការពារក្តី ខៀវ សំផន ជំទាស់ទៅនឹងការការដាក់បង្ហាញនូវកំណត់ហេតុស្តាប់ចម្លើយទាំង ១៨ ដែលបានមកពីសំណុំរឿង ០០៣ និង ០០៤ ដោយផ្អែកលើមូលដ្ឋានថាឯកសារទាំងនោះ គឺជាភស្តុតាងដាក់បន្ទុក។ មេធាវីការពារក្តី ខៀវ សំផន បានស្នើសុំឱ្យតុលាការបដិសេធនូវឯកសារទាំងបីប្រភេទដែលខ្លួនបានលើកឡើងខាងលើ និងស្នើសុំឱ្យតុលាការលុបចោលនូវការបង្ហាញឯកសារ D197.2 របស់សហព្រះរាជអាជ្ញា។ អង្គជំនុំជម្រះបដិសេធការស្នើសុំ និងបានកត់សម្គាល់ថា កំណត់ហេតុស្តាប់ចម្លើយទាំង ១៨ នោះត្រូវបានទទួលយកជាភស្តុតាងនៅក្នុងសេចក្តីសម្រេច E319/22/1។

**ការជំទាស់របស់មេធាវីការពារក្តី នួន ជា ទៅនឹងការបង្ហាញឯកសារគន្លឹះរបស់ព្រះរាជអាជ្ញា**

មេធាវីការពារក្តី នួន ជា បានជំទាស់ទៅនឹងការដាក់បង្ហាញឯកសារគន្លឹះរបស់សហព្រះរាជអាជ្ញាទាក់ទងទៅនឹងកំណត់ហេតុស្តាប់ចម្លើយ ដោយបានលើកឡើងថា កំណត់ហេតុស្តាប់ចម្លើយទាំងនោះ មិនគួរដាក់បង្ហាញនៅក្នុងសវនាការលើឯកសារគន្លឹះនោះទេ និងលើកឡើងបន្ថែមទៀតថា ប្រសិនបើកំណត់ហេតុ

ស្តាប់ចម្លើយត្រូវបានយកមកបង្ហាញ ដូច្នេះសវនាការលើឯកសារគន្លឹះនេះវាក្លាយទៅជាការធ្វើសេចក្តីសន្និដ្ឋានបិទបញ្ចប់ការពិភាក្សាដេញដោលលើភ័ស្តុតាង។ មេធាវីអន្តរជាតិការពារក្តី នួន ជា ក៏បានដើរចេញពីសាលសវនាការ។ មេធាវីការពារក្តីផ្សេងទៀត ក៏បានដើរចេញពីសាលសវនាការផងដែរ។ ប្រធានសវនាការបានប្រកាសផ្អាកកិច្ចនីតិវិធីសវនាការ ដោយសារតែអវត្តមានក្រុមមេធាវីការពារក្តីទាំងពីរក្រុម

**<u>កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធីតាមវិធាន ៨៧ (៣) វិធាននៃភ័ស្តុតាង</u>**

Reclassified

| TC No | OCIJ No | ERN (KH, ENG, FR) | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/3048r | | V00422552-V00422552 | Building a Khmer Rouge Dam | P | | | |
| E3/2348r | | V00172506-V00172506 | Khmer Rouge History of Genocide, part 1 | P | | | |
| E3/2412 | D133/1.6 | 00812343-00812365 | François PONCHAUD: "Kampuchea, a Revolutionary Economy" | P | 00812343; 00812349; 00812360; 00812361 | 00598519; 00598523-00598524; 00598533; 00598534 | 00812343; 00812345; 00812350-00812351 |
| E3/8026 | D166/146 | 00337439-00337456; 00290633-00290646; 00294775-00294784 | Site Identification Report 23 February 2009 OCIJ | P | 00337440-00337441 | 00290634 | 00294776 |
| E3/1783 | D376.3 | 00659257-00659262; 00498179-00498181; 00606764-00606767 | FBIS Report of 22 December 1977 | P | 00659260; 00659261 | 00498181 | 00606766 |
| E3/7414 | D43/IV | 00174119-00174121; 00225265; 00251347 | Colour Copy Excerpt of Confession of YAP Yan Alias SAO | P | 00174121 | 00225265 | 00251347 |

## Other documents (No Change)

| TC No | OCIJ No | ERN (KH, ENG, FR) | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E342.1 | | 00976019-00976115 | Book by Andrew Mertha entitled "Brothers in Arms: Chinese Aid to the Khmer Rouge, 1975-1979" | P | | | |
| E319/21.3.19 | D119/173 | 01065971-01065981; 01076968-01076980 | Written Record of Witness Interview: [REDACTED] | SC | | | |
| E3/20 | | 00231987-00232710; 00237694-00238316; 00638281-00638721 | Book by Elizabeth Becker entitled "When the War was over: Cambodia and the Khmer Rouge Revolution" | P | 00232318-00232319 | 00237945 | 00638501-00638502 |
| E3/1339 | | 00168307-00168399 | Fibis Collection of Dec 1977 | P | NA | 00168335 | NA |
| E3/5513 | D323/54 | 00402438-00402453; 00410228-00410243; 00422286-00422303 | Written Record of Interview of IENG Chham | P | 00402443; 00402444; 00402445; 00402446; 00402447; 00402449 | 00410233;00410234; 00410236; 00410237; 00410238 | 00422292; 00422292; 00422293; 00422295; 00422296; 00422298 |
| E3/35 | D166/166 | 00340559-00340578; 00346145-00346162; 00367717-00367734 | Written Record of Interview of KÈ Pich Vannak | P | | | |

| <u>ដីកា/សេចក្តីសម្រេចផ្ទាល់មាត់៖</u> |
| --- |
| • អនុញ្ញាតឲ្យជនជាប់ចោទ នួន ជា បន្តតាមដានកិច្ចដំណើរការនីតិវិធីសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ ហើយបង្គាប់ឲ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា ដើម្បីបន្តសវនាការពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។ (០៩.១៦)<br>• អង្គជំនុំជម្រះអនុញ្ញាតិឲ្យសហព្រះរាជអាជ្ញា និងមេធាវីនាំមុខ នៅពេលវេលាបន្ថែម ៥០ នាទី ដើម្បីបង្ហាញឯកសារគន្លឹះ ដោយសារមូលហេតុនៃការជំទាស់ផ្សេងៗ។ (១០.៤២)<br>• បង្គាប់អោយអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផន ទៅកាន់មន្ទីរឃុំឃាំងវិញ និងបង្គាប់អោយនាំខ្លួនពួកគាត់ត្រឡប់មកកាន់សាលសវនាការវិញអោយបានមុនម៉ោង ៩.០០ ព្រឹក នៅថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០១៥។ (១១.១៦) |

| <u>កាលវេលាសវនាការបន្ត</u> |
| --- |
| សវនាការនឹងបន្តទៅថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០១៥ ចាប់ផ្តើមពីម៉ោង ០៩.០០ ព្រឹក។ |

ភ្នំពេញ ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០១៥

ក្រឡាបញ្ជី ក្រឡាបញ្ជី

**សែ គុលទុន្នី** **Matthew McCarthy**